# រឿង កូនដំរីឡាឡា



# រឿង កូនដំរីទន្សោ ទ្បាទ្បា

និពន្ធដោយ អ្នកស្រី មុត គន្ធី
គូររូបដោយ លោក សេង វិសាល

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០១២

# រឿង កូនដំរីឡាឡា



នៅក្នុងព្រៃមានសត្វមួយក្រុមកំពុងលេងបោះឈូង ។ កូនដំរី ឡាឡាបានដើរមកដល់ ហើយសួរថា “ខ្ញុំសុំលេងផងបានទេ?” ។



ស្វាឆ្លើយ "ពួកយើងឱ្យឡាឡាឯងលេងបាន តែឯងកុំយកប្រមោយលេងណា!" ។



កូនដំរីឡាឡាងក់ក្បាល ហើយឆ្លើយយ៉ាងលឿន
"បាទ! បាន!បាន! ខ្ញុំមិនយកប្រមោយលេងទេ" ។



ទន្សាយស្រែក "ឈូងអើយ! ឈូង!" ។



ជ្រូក និងសេះលើកដៃចាប់មិនបានធ្វើឱ្យឈូងទៅលើមែកឈើ ។ ពួកគេស្រែកព្រមគ្នា "អូ! ឈូងទៅលើមែកឈើហើយ" ។





ស្វាស្រែក "ទុកឱ្យខ្ញុំឡើងយក!" ។

ស្វាយកបានហើយ បោះទៅឱ្យពពែ ។

ពពែស្រែក "ឈូងអើយ! ឈូង!" ។



កូនដំរីឡូឡាចាប់បាន  រួចក៏ស្រែក
"ចាំទទួលឈ្លួងខ្ញុំវិញម្តង" ។



ពួកគេស្រែកព្រមគ្នា "អូ! ឈូងធ្លាក់ក្នុងទឹកហើយ" ។ ទន្សាយចង់ស្ទុះលោតទៅក្នុងទឹក តែទុចងក់ រួចនិយាយ "អូ! ខ្ញុំចុះមិនបានទេ បើខ្ញុំមិនចេះហែលទឹកផង" ។



សេះនិយាយ "ខ្ញុំយកម្តង! ព្រោះខ្ញុំធំជាងឯង" ។
តែសេះក៏យកឈ្លូងមិនបានដែរ ។



ជ្រូកនិយាយ "ខ្ញុំយកម្តង! ពពែឯងជួយកាន់ដៃខ្ញុំផង ខ្ញុំឈោងយកឈូង ។ អូយ! ខ្ញុំក៏យកមិនបានដែរ!" ។



ស្វានិយាយ "ខ្ញុំយកម្តង" ។ ស្វាក៏យកឈើមកផ្ទុំះ ។



ស្រាប់តែឮសូរ "ប្រូង" ។ ពួកគេស្រែកព្រមគ្នា
"អូ!ស្វាធ្លាក់ទឹកហើយ ជួយស្វាផង!" ។



មានតែកូនដំរីឡាឡាទេ ដែលមានប្រមោយទាញស្វាឡើងពីទឹកមកវិញ រួចនិយាយ "ប្រមោយខ្ញុំក៏អាចឈោងចាប់យកឈូងពីក្នុងទឹកបានដែរ" ។



ពេលឡាឡាយកឈ្លូងបានហើយ ពួកគេទះដៃអបអរសរសើរ "ឡាឡាឯងពិតជាកូនដំរីពូកែមែន  ដូច្នេះឯងអាចយកប្រមោយលេងបានហើយ" ។



ពួកគេនាំគ្នាលេងបន្តទៀតយ៉ាងសប្បាយរីករាយ ។
សំណើចក្អាកក្អាយលាន់ឮកងរំពងពេញព្រៃ ។

ចប់





*Move forward, hand in hand.*

Shanti Volunteer Association

*Stand with people in need around the world.*